# PRESS RELEASE

សេចក្តីប្រកាសព័ត៌មាន

December 17th, 1998

## NOTE TO EDITORS-PHOTO OPPORTUNITY

## The Inauguration Ceremony of the TB Ward

### in Tbaung Khmum Operational District Hospital, Tbong Khmum District, Kompong Cham Province

**December 18th, 1998**
**at 8:30 a.m. at the Tbaung Khmum Operational District Hospital**
**in Tbaung Khmum District, Kampong Cham Province**

This ceremony is to inaugurate a new TB ward in Tbaung Khmum Operational District Hospital in the presence of H.E. Mr. CHEA CHHAY, Under Secretary of State for Health, H.E. Mr. SENG HAKSRUN, Under Secretary of State for Health and Mr. Yutaka NOMURA, Representative of the Embassy of Japan.

The construction of the TB ward was started by Medecins Sans Frontieres Section France in the Tbaung Khmum Operational District Hospital in Tbaung Khmum District, Kampong Cham Province. The Government of Japan funded Medecins Sans Frontieres with US$ 78,311, based on the grant contract singed on November 12th, 1997, through the Japanese Grant Assistance for Grass-Roots Projects Scheme called "KUSANONE", for the construction cost of the TB ward with 40 beds, a toilet, a well and an incinerator. These facilities will enable the Hospital to reduce the infectious risk of tuberculosis for the benefit of around 202,500 residents in the area.

The KUSANONE is the Japan's grant aid to support small-scale, grass-roots projects by NGOs or local authorities and is an important pillar of Japan's economic cooperation to Cambodia. Since its start in 1992, the total amount of US$ 5,885,139 KUSANONE grant has been provided to assist 117 projects in Cambodia to help Cambodian rehabilitation and development efforts at the grass-roots level.

* * *

Editors are invited for reporting and photo coverage.

**Embassy of Japan No. 75, Preah Norodom Blvd. Tel: (023) 217 161/4 Fax: 855 023 216 162**

# PRESS RELEASE                សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៨

## ពិធីសម្ពោធអាគាររបេង
## នៅក្នុងមន្ទីរពេទ្យនៃស្រុកប្រតិបត្តិត្បូងឃ្មុំ នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

**ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨**
**វេលាម៉ោង ៨:៣០ ព្រឹក នៅក្នុងមន្ទីរពេទ្យនៃស្រុកប្រតិបត្តិត្បូងឃ្មុំ**
**នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម**

ពិធីសម្ពោធអាគាររបេងថ្មីមួយខ្នងនៅមន្ទីរពេទ្យនៃស្រុកប្រតិបត្តិត្បូងឃ្មុំ នឹងប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ ឯកឧត្តម ជា ឆាយ អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ឯកឧត្តម សេង ហាក់ស្រ៊ុន អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល និង លោក យូតាកា ណូម៉ូរ៉ា អ្នកតំណាងស្ថានទូតជប៉ុន ។

អាគាររបេងនេះ ត្រូវបានកសាងឡើងដោយអង្គការគ្រូពេទ្យគ្មានព្រំដែននៃប្រទេសបារាំង នៅក្នុងមន្ទីរពេទ្យនៃស្រុកប្រតិបត្តិត្បូងឃ្មុំ ។ ដោយផ្អែកតាមកិច្ចព្រមព្រៀងផ្តល់ជំនួយដែលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាដល់អង្គការគ្រូពេទ្យគ្មានព្រំដែន នូវទឹកប្រាក់ចំនួន ៧៨.៣១១ ដុល្លាអាមេរិក តាមរយៈជំនួយឧបត្ថម្ភរបស់ ជប៉ុនដល់គំរោងការណ៍ទ្រង់ទ្រាយតូច ហៅថា "គូសាណូណេ" ដើម្បីសាងសង់អាគាររបេងមួយខ្នងប្រកបដោយគ្រែ ៤០ បន្ទប់បង្គន់១ខ្នង អណ្តូងទឹកមួយ និងឡសំរាប់ ដុតសំរាមមួយ ។ អាគារនេះនឹងជួយអោយមន្ទីរពេទ្យនេះអាចកាត់បន្ថយបាននូវការឆ្លងរាតត្បាតនៃជំងឺរបេង សំរាប់ជាប្រយោជន៍ដល់ប្រជាជននៅក្នុងតំបន់នេះប្រមាណ ២០២.៥០០ នាក់ ។

"គូសាណូណេ" គឺជាជំនួយឧបត្ថម្ភរបស់ជប៉ុនមួយបែប ដើម្បីជួយដល់គំរោងការណ៍តូចៗនៅតាមមូលដ្ឋាន ដែលផ្តួចផ្តើមគំនិតឡើងដោយអង្គការក្រៅរដ្ឋាភិបាល រឺ ដោយអាជ្ញាធរមូលដ្ឋាន ហើយក៏ជាសសរទ្រូងមួយដ៏សំខាន់នៃជំនួយសហប្រតិបត្តការសេដ្ឋកិច្ចរបស់ជប៉ុននៅកម្ពុជាផងដែរ ។ ចាប់តាំងពីការផ្តើមអនុវត្តជំនួយឧបត្ថម្ភបែបនេះនៅឆ្នាំ ១៩៩២ មក "គូសាណូណេ" បានផ្តល់ទឹកប្រាក់សរុបចំនួន ៥.៨៨៥.១៣៩ ដុល្លាអាមេរិកហើយ សំរាប់ ១១៧ គំរោងការណ៍នៅកម្ពុជា ដើម្បីជួយដល់ការខិតខំប្រឹងប្រែងស្តារ និងអភិវឌ្ឍន៍ឡើងវិញតំបន់ជនបទនៃកម្ពុជា ។

♣♣♣

បណ្តាអ្នកយកពត៌មានទាំងអស់ត្រូវបានអញ្ជើញអោយចូលរួមដើម្បីយកពត៌មាន និងថតរូបភាព

ស្ថានទូតជប៉ុន លេខ ៧៥ មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខៈ ០២៣ ២១៧ ១៦១ /៤ ហ្វាក់លេខៈ ០២៣ ២១៦ ១៦២